ខ_មេដាយមាស :

១_លោក ង៉ែ ហុកឈួន និងអ្នកស្រី ទ៊ុង ស៊ូត្រីន បរិច្ចាគថវិកា ១២៥.០០០$US

២_លោក ង៉ែ ខួន និងអ្នកស្រី តាំង ស៊ាវ៉ែម បរិច្ចាគថវិកា ២៣.០០០$US

គ_មេដាយសំរិទ្ធ :

៣_លោកជំទាវ ម៉ែន សំអន បរិច្ចាគថវិកា ៣.៥០០$US

២_លោក ទៀម គឹត និងអ្នកស្រី អ៊ុន ណារា បរិច្ចាគថវិកា ៣.៥០០$US

មាត្រា ២ : សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និង អភិបាលខេត្តកណ្តាល ត្រូវអនុវត្តអនុក្រឹត្យនេះអោយទទួលបានលទ្ធផលល្អ ។

| នាយករដ្ឋមន្ត្រីទី ១ | នាយករដ្ឋមន្ត្រីទី ២ |
|---|---|
| ព្រះហស្តលេខា និងត្រា | ហត្ថលេខា និងត្រា |
| **នរោត្តម រណឫទ្ធិ** | **ហ៊ុន សែន** |

* * *

រាជធានីភ្នំពេញ , ថ្ងៃទី ២៥ ខែ មិថុនា ឆ្នាំ ១៩៩៦

# ២_សេចក្តីសំរេច

## សេចក្តីសំរេចលេខ ២៤ សសរ

## ស្តីពីការបង្កើតគណៈកម្មការដឹកជញ្ជូនទំនិញពិសេស

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការ តែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី ដែលប្រកាសអោយប្រើដោយព្រះរាជក្រម ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១០៩៤/៨៣ ចុះថ្ងៃទី ២៤ ខែតុលា ឆ្នាំ១៩៩៤ ស្តីពីការស្តីពីការកែសំរួលសមាសភាពរាជរដ្ឋាភិបាល
- តាមសំណើរបស់ឯកឧត្តមអគ្គទេសាភិបាលធនាគារជាតិនៃកម្ពុជា

## សំរេច

**ប្រការ ១ :** បង្កើតគណៈកម្មការចំរុះមួយ ទទួលបន្ទុកដឹកទំនិញពិសេសសំរាប់ធនាគារជាតិ នៃកម្ពុជា ដែលមានសមាសភាពដូចខាងក្រោម :

១–តំណាងក្រសួងមហាផ្ទៃ ជាប្រធាន

២–តំណាងក្រសួងការពារជាតិ ជាអនុប្រធានទទួលបន្ទុកការពារក្នុងការដឹកជញ្ជូន

៣–តំណាងធនាគារជាតិនៃកម្ពុជា ជាសមាជិក

**ប្រការ ២ :** គណៈកម្មការចំរុះនេះ ត្រូវចូលរួមប្រជុំតាមការអញ្ជើញរបស់ប្រធាន ដើម្បីពិភាក្សាបែងចែកភារកិច្ចដឹកជញ្ជូនទំនិញពិសេស ។

**ប្រការ ៣ :** សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ សហរដ្ឋមន្ត្រី ក្រសួងការពារជាតិ និង អគ្គទេសាភិបាលធនាគារជាតិនៃកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តសេចក្តីសំរេចនេះ តាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃឡាយព្រះហស្តលេខា និង ហត្ថលេខាតទៅ ។

| | |
|---|---|
| នាយករដ្ឋមន្ត្រីទី ១ | នាយករដ្ឋមន្ត្រីទី ២ |
| ព្រះហស្តលេខា និងត្រា | ហត្ថលេខានិងត្រា |
| **នរោត្តម រណឫទ្ធិ** | **ហ៊ុន សែន** |

* * *